**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិគាំពារសង្គម**
លេខ:......៤......ក.ជ.គ.ស.........

*ថ្ងៃ ពុធ ២ កើត ខែ ភទ្របទ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ កញ្ញា គ.ស. ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី១៣

នៅព្រឹកថ្ងៃទី ៤ ខែកញ្ញា គ.ស. ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម លើកទី១៣ ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលបន្ថែមលើសេចក្តីព្រាង **"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥"** ក្នុងគោលបំណងធ្វើឱ្យសេចក្តីព្រាងក្របខណ្ឌគោលនយោបាយនេះ កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបាន ក្នុងបរិបទសេដ្ឋកិច្ច-សង្គមកម្ពុជា។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផងដែរ និងបានផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

## ១. សារបាននៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម៖

ដើម្បីឆ្លើយតបនឹងគោលដៅ ដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០, កម្ពុជាត្រូវការជាចាំបាច់នូវប្រព័ន្ធគាំពារសង្គមមួយដែលកាន់តែរឹងមាំ។ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាត្រូវតែបន្តសក្តានុពលក្នុងការបោះជំហានទៅមុខបន្ថែមទៀត ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ចំពោះបញ្ហាប្រឈម ទាំងក្នុងកម្រិតសកល និងកម្រិតជាតិ តាមរយៈការបែងចែកធនធានឡើងវិញឱ្យកាន់តែប្រសើរ ចូលរួមធានាបាននូវសមធម៌ បរិយាបន្ន និងសាមគ្គីធម៌ក្នុងសង្គម។

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ, បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញ **"ក្របខណ្ឌគោល-នយោបាយជាតិគាំពារសង្គម ២០១៦-២០២៥"**, ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជាបានបោះជំហានយ៉ាងមុតមាំ។ ទោះយ៉ាងនេះក្តី, តាមការចង្អុលបង្ហាញរបស់ក្របខណ្ឌគោលនយោបាយនេះ, ក្រុមប្រឹក្សា-ជាតិគាំពារសង្គម ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានសម្របសម្រួលគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលបានដាក់ចេញកន្លងមក ដើម្បីឱ្យ **"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥"** មានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព សំដៅអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជាឱ្យឈានដល់ដំណាក់កាលថ្មីមួយដែលមានលក្ខណៈកាន់តែរឹងមាំ កាន់តែប្រមូលផ្តុំ និងកាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្ត ។

ក្នុងន័យនេះ, សេចក្តីព្រាង "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" គឺជាការធ្វើបច្ចុប្បន្នកម្មលើ "ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥" ឱ្យស្រប តាមបរិបទជាក់ស្តែងនៅកម្ពុជា ។

## ២. ខ្លឹមសារសង្ខេបនៃសេចក្តីព្រាង " ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥"៖

សេចក្តីព្រាង " **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥**" ផ្តោតលើការ កែទម្រង់អភិក្រមនៃប្រព័ន្ធគាំពារសង្គម ពីអភិក្រមសសរស្តម្ភទាំង ២ គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធ សន្តិសុខសង្គម ទៅជាអភិក្រមហានិភ័យនៃវដ្តជីវិត ដោយបានរំលេចនូវហានិភ័យចំនួន ៧ រួមមាន៖ មាតុភាព និងកុមារភាព, សុខភាព, ការងារ, ភាពគ្មានជម្រក, និកម្មភាព, ពិការភាព, និង ជរាភាពនិងឧត្តរជីវី ។

"**ក្របខណ្ឌគោលនយោបាយជាតិ**" ថ្មីនេះ ក៏នឹងបន្តពង្រឹងអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម ដែល មាន **៣ កម្រិត** គឺកម្រិតគោលនយោបាយ, កម្រិតនិយ័តករ, និងកម្រិតប្រតិបត្តិករ ដើម្បីធានាឱ្យបាន នូវប្រតិតុល្យការ តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធគាំពារសង្គមទាំងមូល ទន្ទឹមនឹងការបន្តគិតគូរ ពីកិច្ចការឆ្លងវិស័យ ដែលជាកត្តាជំរុញឱ្យការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមបោះជំហានទៅមុខកាន់តែលឿន។ កិច្ចការឆ្លងវិស័យទាំងនេះ រួមមាន៖ យន្តការដោះស្រាយវិវាទ និងការទទួលមតិត្រឡប់, ការកំណត់ អត្តសញ្ញាណអត្ថគាហក, ប្រព័ន្ធគាំពារសង្គមឌីជីថល, ការបញ្ជ្រាបការយល់ដឹង, ទំនាក់ទំនង និង ការផ្សព្វផ្សាយ, គោលនយោបាយគាំទ្រ, និងយន្តការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍។

តាមរយៈការពិនិត្យ និងពិភាក្សា, អង្គប្រជុំ ក៏បានសម្រេចផ្តល់ការយល់ព្រមលើសេចក្តីព្រាង "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥**" ដែលត្រូវបានរៀបចំជា **៧ ផ្នែក** សំខាន់ៗ គឺ៖

១. ទិដ្ឋភាពទូទៅ,

២. អភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា,

៣. អន្តរាគមន៍គាំពារសង្គម,

៤. កិច្ចការឆ្លងវិស័យ,

៥. អភិបាលកិច្ចប្រព័ន្ធគាំពារសង្គម,

៦. យន្តការអនុវត្ត និងយន្តការតាមដាន និងវាយតម្លៃ, និង

៧. សេចក្តីសន្និដ្ឋាន

ជាចុងក្រោយ, អង្គប្រជុំ ក៏បានសម្រេចលើសេចក្តីព្រាងចុងក្រោយនៃ "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥**" នេះ និងគោរពស្នើសុំដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីស្នើសុំ ពិនិត្យ និងអនុម័ត ក្នុងពេលដ៏ឆាប់ខាងមុខ។

**ក្រុមប្រឹក្សាជាតិគាំពារសង្គម**

NATIONAL SOCIAL PROTECTION COUNCIL